# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសពត៌មាន</u>

# ពិធីជួបជុំអតីតនិស្សិតកម្ពុជាដែលធ្លាប់សិក្សានៅប្រទេសអូស្ត្រាលី

អតីតនិស្សិតឆ្នើមកម្ពុជាដែលធ្លាប់សិក្សានៅប្រទេសអូស្ត្រាលី រួមមាន ធុរជន មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល បញ្ញាវន្ត និងថ្នាក់ដឹកនាំនៃអង្គការសង្គមស៊ីវិលមួយចំនួន នឹងជួបជុំគ្នានៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នាសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ក្នុងពិធីជួបជុំអតីតនិស្សិតកម្ពុជាដែលធ្លាប់សិក្សានៅប្រទេសអូស្ត្រាលី។កម្មវិធីនេះរៀបចំឡើងដោយស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា រួមជាមួយសមាគមអតីតនិស្សិតកម្ពុជាមកពីប្រទេសអូស្ត្រាលី (AAA-C )។

ពិធីជួបជុំគ្នានេះ នឹងផ្តល់ឱកាសអោយអតីតនិស្សិតកម្ពុជាមកពីអូស្ត្រាលីទាំងអស់ចែករំលែកនូវអនុស្សាវរីយ៍ អបអរសាទរសមិទ្ធិផលរបស់ខ្លួន រំលឹកមិត្តភាពចាស់ៗ ព្រមទាំងកសាងទំនាក់ទំនងថ្មីៗ ជាមួយបុគ្គលឆ្នើមនានាដែលជោគជ័យក្នុងអាជីពនៅកម្ពុជា។

នៅក្នុងពិធីជួបជុំគ្នានេះផងដែរ AAA-C នឹងប្រគល់រង្វាន់ជូន អតីតនិស្សិតឆ្នើមកម្ពុជាដែលបញ្ចប់ការសិក្សាពីអូស្ត្រាលីមួយរូប ដែលបានចូលរួមចំនែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍នៅកម្ពុជា។

លោកជំទាវ **អាលីសុន បើរ៉ូ (Alison Burrows)** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា« កម្មវិធីនេះគឺជាឱកាសសំរាប់ឆ្លុះបញ្ចាំងពី ការចូលរួមរបស់អតីតនិស្សិតកម្ពុជាដែលបញ្ចប់ការសិក្សាពីអូស្ត្រាលីទាំងអស់ ក្នុងការរួមចំណែកអភិវឌ្ឍនៅកម្ពុជា។»

លោកជំទាវបន្តទៀតថា« អតីតនិស្សិតដែលបានបញ្ចប់ការសិក្សាពីប្រទេសអូស្ត្រាលីបានក្លាយទៅជា រដ្ឋមន្ត្រី ឯកអគ្គរាជទូត មន្ត្រីជាន់ខ្ពស់ ប្រធានក្រុមហ៊ុន ព្រឹទ្ធបុរសរង ប្រចាំសកលវិទ្យាល័យ និងអ្នកដឹកនាំតាមសហគមន៍នានា។»

«ខ្ញុំមានមោទនភាពដោយបានឃើញនូវការចូលរួមរបស់អូស្ត្រាលី នៅក្នុងការអភិវឌ្ឍន៍នៅកម្ពុជា តាមរយៈការបណ្តុះបណ្តាលនិស្សិតឆ្នើមមក ពីគ្រប់ខេត្ត ក្រុងនៃប្រទេសកម្ពុជា។»

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

តាំងពីចាប់ផ្តើមកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅឆ្នាំ១៩៩៤ មកដល់ពេលនេះ មាននិស្សិតឆ្នើមកម្ពុជាច្រើនជាង៦០០នាក់ បានទទួលអាហារូបករណ៍នេះទៅសិក្សានៅប្រទេសអូស្ត្រាលី។ ក្រៅពីនេះក៏មានសិស្សនិស្សិតកម្ពុជាផ្សេងទៀត ដែលមានចំនួនច្រើនជាងនេះ បានទៅសិក្សានៅប្រទេសអូស្ត្រាលី ជាលក្ខណៈឯកជន ឬតាមរយៈកម្មវិធីអាហារូបករណ៍ដទៃទៀត។

ការសិក្សានៅប្រទេសអូស្ត្រាលីគឺ ជារបត់នៃការផ្លាស់ប្តូរបទពិសោធន៍ក្នុងជីវិតរបស់និស្សិតកម្ពុជា។ អូស្ត្រាលីក៏កំពុងតែក្លាយជាគោលដៅសិក្សាដ៏ពេញនិយមសំរាប់និស្សិតកម្ពុជាផងដែរ។ ចំនួននៃនិស្សិតកម្ពុជាដែលបានទៅសិក្សានៅប្រទេសអូស្ត្រាលី បានកើនពី៥០០នាក់ក្នុង១ឆ្នាំ នៅឆ្នាំ២០០២ ដល់ប្រមាណជា ២០០០នាក់ក្នុង១ឆ្នាំ នៅឆ្នាំ២០១៤។

ស្ថានទូតអូស្ត្រាលីមានក្តីសោមនស្សរីករាយ ដែលពិធីជួបជុំគ្នានេះក៏បានទទួលការឧបត្ថម្ភពីសំណាក់ សកលវិទ្យាល័យលំដាប់កំពូលនៅអូស្ត្រាលីមួយចំនួនដូចជា Monash University; University of Technology Sydney: Insearch; University of New South Wales; and La Trobe University.

សំរាប់ពត៌មានបន្ថែមពីកម្មវិធីនេះ សូមមើល www.cambodia.embassy.gov.au

**ទំនាក់ទំនងពត៌មាន៖ លោក សាយម៉ុន ហ្វៀលឡូវ (Simon Fellows)**

**ស្ថានទូតអូស្ត្រាលីភ្នំពេញ**

**ទូរស័ព្ទលេខ ០២៣ ២១៣ ៤៧០**

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥**